**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការក្រុងភ្នំពេញ**

**ជាក់ជូនការិយាល័យព្រះរាជអាជ្ញា**

---

# បណ្តឹងព្រហ្មទណ្ឌ

---


**ដើមបណ្តឹង:**

Michiel PESTMAN & Andrew IANUZZI

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ប្រអប់សំបុត្រលេខ ៧១ (បន្ទប់លេខ ២០១)

ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**ការិយាល័យព្រះរាជអាជ្ញា**

**យ៉េត ចរិយា**

ប្រធានព្រះរាជអាជ្ញា

អគារ ៣១, វិថីមុន្នីរ៉េត

ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## I. **សេចក្តីផ្តើម**

១ អនុលោមតាមមាត្រា ០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ហៅកាត់ថា "កនព"), ដើមបណ្តឹងដែលជាមេធាវីការពារក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា "អវតក") សូមដាក់បណ្តឹងព្រហ្មទណ្ឌនេះជូនការិយាល័យព្រះរាជអាជ្ញា នៃតុលាការក្រុងភ្នំពេញ (ហៅកាត់ថា "តកភ")។ ដើមបណ្តឹងជាជនរងគ្រោះ[1] នៃការបំពានលើមាត្រាទី ៥២២, ៥៣៨, ៥៤៦, និង ៥៤៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[2] (ហៅថា "ក្រមព្រហ្មទណ្ឌ") និង/ឬ បញ្ញត្តិដូចគ្នានឹងច្បាប់ព្រហ្មទណ្ឌកម្ពុជាដែលកំពុងអនុវត្តផ្សេងៗទៀត[3]។ ជាពិសេសដើមបណ្តឹង សូមលើកឡើងថា ការជ្រៀតជ្រែកមិនសមស្របដោយមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា (ហៅកាត់ថា "ររក" ឬ "រដ្ឋាភិបាល") ព្រមទាំងការខកខានរបស់មន្ត្រីរដ្ឋាភិបាលជាក់លាក់មួយចំនួន មិនឆ្លើយតបទៅនឹងដីកាកោះហៅរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា "កសចស") ថាជា "បទល្មើសប្រឆាំងនឹងជាតិ"[4] និងបានបន្ទាបបន្ថោកអធិបតេយ្យភាពនៃនីតិវិធីសំណុំរឿង ០០២ នៅចំពោះមុខ អវតក។

## II **ប្រវត្តិអង្គហេតុ**

២ ចាប់តាំងពីការបង្កើត អវតក មកសមាជិករដ្ឋាភិបាលបានជ្រៀតជ្រែកយ៉ាងសកម្មក្នុងកិច្ចការតុលាការ។ ជាពិសេសបុគ្គលខាងក្រោមនេះបានប្រព្រឹត្តសកម្មភាពជាក់លាក់ដូចតទៅនេះ៖

---

[1] សូមមើលមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើសអាចដាក់ពាក្យប្តឹងបាន។

[2] សូមមើលព្រះរាជក្រម នស/រកម/១១០៩/០២២, ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១១ (ប្រកាសឲ្យប្រើ "ក្រមនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំលើកទី៣ នីតិកាលទី៤ ហើយដែលត្រូវបានព្រឹទ្ធសភាបានអនុម័យយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៩ សម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២)

[3] សូមមើល ឧទាហរណ៍, បទប្បញ្ញត្តិចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ស្តីពីប្រព័ន្ធតុលាការ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ("ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់") ។ កំណត់សំគាល់. ផ្អែកលើព័ត៌មាន និងការជឿជាក់នៅមុនការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌសព្វថ្ងៃនេះ ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ឆ្នាំ១៩៩២ គឺជាច្បាប់ព្រហ្មទណ្ឌដែលអនុវត្តនៅកម្ពុជា ។

[4] សូមមើលកថាខណ្ឌទី៣ ខាងក្រោម ។

ក. **គង់ សំអុល:** នៅខែ កក្កដា ឆ្នាំ ២០០៩ រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង បានរារាំងយ៉ាងសកម្មមិនឲ្យលិខិតរបស់ កសចស យាងព្រះបាទ **នរោត្តម សីហនុ** ដើម្បីផ្តល់សក្ខីកម្មនៅ អវតក ក្នុងសំណុំរឿង ០០២ ទៅដល់ដៃព្រះរាជបិតា[5]។

ខ. **ហ៊ុន សែន:** ខែ កញ្ញា ឆ្នាំ ២០០៩ នៅក្នុងសន្ទរកថា ជាសាធារណៈនៅខេត្តតាកែវ លោកនាយករដ្ឋមន្ត្រីបានទទួលស្គាល់ការបដិសេធឲ្យមានសាក្សីជាក់លាក់ នៅចំពោះមុខ អវតក[6]។

គ. **ជា ស៊ីម, ហេង សំរិន, ហោ ណាំហុង, គាត ឈន់, អ៊ុក ប៊ុនឈឿន និង ស៊ីម កា៖** ត្រូវបានកោះហៅដោយ កសចស នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩[7] ប៉ុន្តែគ្មានអ្នកណាម្នាក់ក្នុងចំណោមអតីតកម្មាភិបាលខ្មែរក្រហម ដែលមានប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា រដ្ឋមន្ត្រីក្រសួងការបរទេស, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសមាជិកព្រឹទ្ធសភាពីររូបមកពីគណបក្សប្រជាជន (ទាំងអស់នេះហៅថា "សាក្សីខាងក្នុងទាំងប្រាំមួយរូប") ចូលខ្លួនតាមដីកាឡើយ។ ហើយក៏គ្មានហេតុផលត្រឹមត្រូវ ចំពោះការបដិសេធចូលខ្លួនត្រូវបានបង្ហាញនោះដែរ។

---

[5] សូមមើលឯកសារ D-122/5 លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនលោក គង់ សំអុល ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩, ERN 00350280 ។ ឯកសារ D-122/5/1 លិខិតពីលោក គង់ សំអុល ផ្ញើមកសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៩, ERN 00351389–00351392 ។ ឯកសារ D-122/5/3 លិខិតពីលោក គង់ សំអុល ផ្ញើមកសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩, ERN 00355672–00355674 ។ កំណត់សំគាល់៖ ចៅក្រម យូរ ប៊ុនឡេង បានបដិសេធមិនចុះហត្ថលេខាលើលិខិតទាំងនេះទេ ។

[6] យោងតាមអត្ថបទបកប្រែដែលផ្តល់ដោយផ្នែកកិច្ចការសាធារណៈនៃ អវតក នាយករដ្ឋមន្ត្រីបានធ្វើការកត់សម្គាល់ដូចខាងក្រោម៖ "តុលាការហ្នឹងទាស់គ្នាពេញតែតុលាការ។ គ្មានរឿងស្អីទេ ដើម្បីពន្យាការចាយលុយថែមតែប៉ុណ្ណឹងទេ បើគេឲ្យមកចាយទៅ តែបើនាប់អស់លុយក៏ហីទៅ។ កុំមកចង់ដាក់កំរិត ថាត្រូវតែចុះហត្ថលេខាទើបឲ្យលុយ ខ្ញុំប្រកាស ឮមិនឲ្យទេ ហីទៅអស់លុយឲ្យរហ័ស នឹងអាលដើរចេញទៅ អីក៏វាសាំញ៉ាំមាំម្ល៉េះ។ ហើយឥឡូវដើរបំភ័យ។ ថ្ងៃមុនដើរទៅរកឯណាហៅនរណាឡើងធ្វើសាក្សីឯណា ចង់ហៅអ្នកនេះ អ្នកនោះធ្វើសាក្សី អត់ទេ កុំរញ៉េរញ៉ៃច្រើនពេក។ (បញ្ជាក់បន្ថែម) ។

[7] សូមមើលឯកសារ **D-136/2/1**, "ដីកាដោះហៅសាក្សី" ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩, ERN 00387202–00387203 ។ ឯកសារ **D-136/3/1**, "ដីកាដោះហៅសាក្សី" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩, ERN 00401699–00401700 ។ ឯកសារ **A-299/1** "ដីកាដោះហៅសាក្សី" ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩, ERN 00387141–00387142។ ឯកសារ **A-296/1** "ដីកាដោះហៅសាក្សី" ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩, 00387137–00387138 ។ ឯកសារ **A-298/1**, "ដីកាដោះហៅសាក្សី" ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩, ERN 00387139–00387140 ។ ឯកសារ **A-297/1**, "ដីកាដោះហៅសាក្សី" ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩, ERN 00380693–00380694 ។

ឃ. **ខៀវ កាញារិទ្ធ** នៅខែ តុលា ឆ្នាំ ២០១០ រដ្ឋមន្ត្រីក្រសួងព័ត៌មានបាននិយាយជាសាធារណៈថា បើទោះជាសាក្សីទាំងប្រាំមួយនាក់ "អាចបង្ហាញខ្លួនដោយស្ម័គ្រចិត្ត ក៏ប៉ុន្តែជំហររបស់រដ្ឋាភិបាលគឺថា គាត់មិនគួរផ្តល់សក្ខីកម្មទេ។ គាត់ថែមទាំងនិយាយថាមន្ត្រីបរទេសដែលធ្វើការនៅតុលាការអាច "វេចខោអាវ និងត្រឡប់ទៅផ្ទះវិញទៅ" ប្រសិនបើគេមិនពេញចិត្តនឹងសេចក្តីសម្រេច"[8]។ រហូតមកដល់ពេលនេះគ្មានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងប្រាំមួយចូលខ្លួនដោយស្ម័គ្រចិត្តផ្តល់សក្ខីកម្មសម្រាប់សំណុំរឿង ០០២ នៅចំពោះមុខមន្ត្រីតុលាការឡើយ។

ង. **ខៀវ សុភ័គ៖** នៅខែ មិថុនា ឆ្នាំ ២០១០ អ្នកនាំពាក្យក្រសួងមហាផ្ទៃ "បានគាំទ្រជំហររដ្ឋាភិបាលជំទាស់និងការស៊ើបអង្កេត [សំណុំរឿង ០០៣ និង ០០៤] ដោយដកស្រង់ការព្រមានរបស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** លើបញ្ហាអស្ថេរភាពថា៖ "មានតែមេដឹកនាំជាន់ខ្ពស់តែប្រាំនាក់ទេ ដែលនឹងកាត់ទោស"។ លោកឧត្តមសេនីយបាននិយាយទៀតថា "មិនមែនប្រាំមួយទេ គឺមានតែប្រាំ។ តុលាការត្រូវតែធានាអំពីស្ថេរភាព និង សន្តិភាពជាតិ"។ "យើងមិនចង់មានជំលោះ និងអស្ថេរភាពក្នុងស្រុកទេ"[9]។

ច. **ហ៊ុន សែន៖** នៅខែ តុលា ឆ្នាំ ២០១០ លោកនាយករដ្ឋមន្ត្រីបានប្រាប់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ Ban Ki-moon ថា សំណុំរឿង ០០៣ និង ០០៤ មិនត្រូវ "បានអនុញ្ញាតទេ"[10] ។

---

[8] Sebastian Strangio & Cheang Sokha, *ព្រឹត្តិប័ត្រ ឌឹ ភ្នំពេញប៉ុស្ត៍* "សក្ខីកម្មរបស់រដ្ឋាភិបាលអាចបង្កឲ្យមានភាពលំអៀង ដល់សាលាក្តី: ('Gov't testimony could bias KRT: PM') ចុះផ្សាយថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩ ។

[9] Douglas Gillison, "សាលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតទៅលើជនសង្ស័យថ្មីប្រាំនាក់នៃរបបខ្មែរក្រហម" ព្រឹត្តិប័ត្រ *ឌឹ កាំបូឌាដាលី* ចេញផ្សាយថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ២០១០ ។ កំណត់សំគាល់៖ សេចក្តីប្រកាសនេះកើតឡើងនៅពេលដែលចៅក្រម យូ ប៊ុនឡេង លុបចេញហត្ថលេខារបស់គាត់ចេញពីដីកា ចាត់ឲ្យស៊ើបសួរជំនួសនៅក្នុងករណី ០០៣ និង ករណី០០៤" ។ សូមមើលអនុស្សរណៈផ្ទៃក្នុងរបស់ កសចស ដែលបញ្ជូនពី លោកចៅក្រម យូ ប៊ុនឡេង ទៅឲ្យចៅក្រម Marcel Lemonde ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០ ដែលមានកម្មវត្ថុ "ឯកសារ សំណុំរឿង ០០៣ និង ០០៤" (អត្ថបទបកប្រែមិនផ្លូវការពីភាសាបារាំង)។ Douglas Gillison, "ចៅក្រមនៅសាលាក្តីខ្មែរក្រម ដកខ្លួនចេញពីការស៊ើបអង្កេតថ្មី" ('Khmer Rouge Tribunal Judge Backs Out of New Inquiries) ព្រឹត្តិប័ត្រ *ឌឹ កាំបូឌាដាលី* ចុះផ្សាយថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ។ Douglas Gillison, "ចៅក្រមនៅសាលាក្តីខ្មែរក្រមមិនចុះ ហត្ថលេខាដើម្បីឲ្យ បើកកិច្ចស៊ើបអង្កេតថ្មី" (KR Judge Does Not Sign On To New Investigations) ព្រឹត្តិប័ត្រ *ឌឹ កាំបូឌាដាលី* ចុះផ្សាយថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ ។

[10] សូមមើលអត្ថបទចុះផ្សាយរបស់ AFP "នាយករដ្ឋមន្ត្រីកម្ពុជាមិនឲ្យមានការជំនុំជម្រះលើសំណុំរឿងខ្មែរទីបី" (Cambodian PM Says No Third Khmer Rouge Trial), ចុះផ្សាយថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ (លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រាប់

ឆ. **ខៀវ កាញារិទ្ធ៖** នៅខែ ឧសភា ឆ្នាំ ២០១១ លោករដ្ឋមន្ត្រីក្រសួងព័ត៌មាន បាននិយាយថា ជនជាតិបរទេសដែលចង់ស៊ើបអង្កេតសំណុំរឿង ០០៣ និង ០០៤ "គួរវេចខោអាវ និងត្រឡប់ទៅផ្ទះវិញទៅ"[11]។

ជ. **ហោ ណាំហុង ៖** នៅខែ តុលា ឆ្នាំ ២០១១ រដ្ឋមន្ត្រីក្រសួងការបរទេសត្រូវបានដកស្រង់សំដីថា "មានតែកម្ពុជាទេអាចសម្រេចថា មានជនសង្ស័យបន្ថែមប៉ុន្មាននាក់ទៀត ដែលសាលាក្តីខ្មែរក្រហមនឹងកាត់ទោស"[12]។

ឈ. **ផៃ ស៊ីផាន៖** នៅខែ តុលា ឆ្នាំ ២០១១ អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី បាននិយាយថា ការចាកចេញរបស់ចៅក្រម Blunk ពីតុលាការបង្ហាញថា គាត់មិនយល់ពីគោលការណ៍របស់តុលាការកូនកាត់។ លោកបាននិយាយថា "លោកចៅក្រម [Blunk] មិនយល់ពីស្មារតីនៃការបង្កើត អវតក ដែលជាការសហការរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ"។ "យើងនឹងឈរលើជំហររបស់យើងទាក់ទងនឹង អវតក នេះ។ វានឹងមិនមានករណី ០០៣ និង ០០៤ នោះទេ"។ *"រដ្ឋាភិបាលមិនចង់បានការបរាជ័យ ដែលជាមូលហេតុ យើងអនុញ្ញាតឲ្យមានតែសំណុំរឿង ០០២ កើតមានឡើងប៉ុណ្ណោះ"*[13]។

---

លោកអគ្គលេខាអង្គការសហប្រជាជាតិ Ban Ki-moon ដែលកំពុងបំពេញទស្សនកិច្ចនៅកម្ពុជានៅថ្ងៃពុធថាការជំនុំជម្រះលើករណីទី២នៃមេដឹកនាំខ្មែរក្រហម ដែលនឹងចាប់ផ្តើមនៅដើមឆ្នាំក្រោយ គឺជាករណីចុងក្រោយបង្អស់ហើយ)។ លោក ហ៊ុន សែន "បញ្ជាក់យ៉ាងច្បាស់ថាករណីទី៣ មិនអនុញ្ញាតទេ" រដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង បានប្រាប់អ្នកយកសារព័ត៌មានបន្ទាប់ពីជំនួបរវាងលោក Ban Ki-moon ជាមួយលោកនាយករដ្ឋមន្ត្រីថា "យើងត្រូវគិតពីសន្តិភាពនៅកម្ពុជា") (We have to think about peace in Cambodia) ។

[11] James O'Toole, *ព្រឹត្តិប័ត្រ ឌឹ ភ្នំពេញប៉ុស្ត៍* "ការមិនចុះសម្រុងគ្នាកើតឡើងនៅក្នុងករណី ០០៣" ចុះផ្សាយថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១ 'Wrangling ahead in Case 003' (ប៉ុន្តែបញ្ហាទាំងនេះត្រូវបានដោះស្រាយរួចហើយ បញ្ហាដែលធំគឺថាតើរដ្ឋាភិបាលកម្ពុជានឹងបន្តជំហររបស់ខ្លួនជំទាស់នឹងករណី ០០៣ និងករណី ០០៤ ដែលនៅតែមិនទាន់ដោះស្រាយ ដែរឬអត់។ ឆ្លើយទៅនឹងសេចក្តីថ្លែងរបស់លោក Cayley ពីសប្តាហរណ៍កន្លងទៅ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ខៀវ កាញារិទ្ធ បានធ្វើព្រមានម្តងហើយម្តងទៀតទៅលើមន្ត្រីអន្តរជាតិរបស់តុលាការអំពីករណីទាំងនេះ ដោយបានលើកឡើងថាអ្នកដែលជាប់ពាក់ព័ន្ធក្នុងការស៊ើបអង្កេត ត្រូវវេចខោអាវ និងត្រឡប់ទៅផ្ទះវិញទៅ"។

[12] Julia Wallace & Neou Vannarin, ព្រឹត្តិប័ត្រ *ឌឹ កាំបូឌាដាលី* "ខ្មែរក្រហមបន្ថែមទៀតចាប់ខ្លួននៅក្នុងដែកម្ពុជា, 'Additional KR arrests in Cambodia's han", *ហោ ណាំហុង* លើកឡើងនៅថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១១ ។

[13] Alice Foster & Phorn Bopha, ព្រឹត្តិប័ត្រ *ឌឹ កាំបូឌាដាលី* "ចៅក្រមនៅសាលាក្តីខ្មែរក្រហមលាឈប់ពីតំណែងដោយសារការគាបសង្កត់ពីរដ្ឋាភិបាល" 'Judge Resigns KR Court Over Gov't Pressure', ចុះផ្សាយថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ ។

ការលើកឡើងជាសាធារណៈទាំងនេះ ដូចដែលចៅក្រមកម្ពុជាមួយរូបក្នុងតុលាការនេះបញ្ជាក់ថា ការជ្រៀតជ្រែករបស់រដ្ឋាភិបាលគឺជារឿងពិតនៅ អវតកៈ "តើយើងអាចនិយាយថា តុលាការនេះជាគំរូនៃឯករាជ្យយ៉ាងដូចម្តេច ប្រសិនបើរដ្ឋាភិបាល *មិនអនុញ្ញាតឲ្យយើងបំពេញការងាររបស់យើងនោះ?*"[14]

## III ច្បាប់ជាធរមាន

៣ គន្ថីទី៤ នៃក្រមព្រហ្មទណ្ឌ កំណត់ "បទល្មើសនានា ប្រឆាំងនឹងជាតិ"។ បទល្មើសទាំងនោះ មានក្នុងមាតិកាទី ២ និយាយពីបណ្តឹងនៃ "ការប៉ះពាល់ដល់វិស័យយុត្តិធម៌" ដែលមាតិកានេះ ក្នុងចំណោមការបំពានផ្សេងទៀត ក៏មាននិយាយអំពីបណ្តឹងជាក់លាក់នៃ "ការប៉ះពាល់ដល់ស្ថាប័នយុត្តិធម៌" (ជំពូកទី ១)។ "ការប៉ះពាល់ដល់សកម្មភាពរបស់តុលាការ" (ជំពូកទី ២)។ និង ការបំពានលើសេចក្តីសម្រេចខ្លះៗ របស់តុលាការ" ជំពូកទី ៤។ ភាពពាក់ព័ន្ធជាក់លាក់នឹងបណ្តឹងនេះ មានក្នុងមាត្រាទាំងប្រាំពីរដូចខាងក្រោម៖

**មាត្រា ៥២០ បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ**

អំពើរបស់អ្នករាជការសាធារណៈក្នុងមុខការរបស់ខ្លួន ដែលមិនព្រមអនុវត្តសាលដីកា សាលក្រម ដីកា ឬរាល់បញ្ជារបស់អាជ្ញាធរតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

**មាត្រា ៥២២ បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដើម្បីធ្វើសម្ពាធលើយុត្តាធិការ**

ការផ្សព្វផ្សាយមុនសេចក្តីសម្រេចជាស្ថាពររបស់តុលាការនូវអត្ថាធិប្បាយ ដោយគោលដៅធ្វើការគាបសង្កត់ទៅលើតុលាការដែលទទួលបណ្តឹង ដើម្បីជះឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀលទៅ ១ ០០០ ០០០ (មួយលាន) រៀល។

**មាត្រា ៥២៥ ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៥២០ (បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ) [...] នៃក្រមនេះត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ។

[14] James Goldston, *Wall Street Journal*, Op-Ed, "តុលាការកម្ពុជាស្ថិតនៅក្រឡែងកែង" ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១០ (បញ្ជាក់បន្ថែម) ។

**មាត្រា ៥៣៨ បទបដិសេធក្នុងការចូលខ្លួន**

រាល់បុគ្គលណាដែលត្រូវបានកោះហៅឲ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬចៅក្រមស៊ើបសួរ ឬមុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះហៅនោះដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល។

**មាត្រា ៥៤៦ បទសម្លុតសាក្សី**

គ្រប់អំពើសម្លុត ដែលប្រព្រឹត្តដោយចារីតែម្នាក់ឯង ឬដោយមានការព្រមព្រៀងជាមួយតតិយជន ដើម្បីញុំាងឲ្យផ្តល់ដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរនូវសក្ខីកម្មភូតកុហក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះ សម្តែងចេញជាលទ្ធផល[15]។

**មាត្រា ៥៤៩ បទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់លើសាក្សី**

ការផ្សព្វផ្សាយមុនសេចក្តីសម្រេចស្ថាពររបស់តុលាការនូវអត្ថាធិប្បាយ ដែលមានគោលបំណងធ្វើការគាបសង្កត់លើសាក្សីដើម្បីជះឥទ្ធិពលទៅលើសក្ខីកម្មរបស់សាក្សីនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០ ០០០ (មួយម៉ឺន) រៀល ទៅ ១០០ ០០០ (មួយសែន) រៀល។

**មាត្រា ៥៨៦ បទចាត់វិធានការសំដៅរារាំងការអនុវត្តច្បាប់ និងស្ថានទម្ងន់ទោស**

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោតនៅក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការសម្រាប់រារាំងការអនុវត្តច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះសម្តែងចេញជាលទ្ធផល។

[15] សូមមើលមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ឆ្នាំ១៩៩២ "ជនណាដែលគំរាមកំហែង សំឡុត ឬធ្វើការគាបសង្កត់លើសាក្សីណាមួយក្នុងនីតិវិធីតុលាការ ត្រូវមានទោសមជ្ឈិមពីបទសំឡុត ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ២ឆ្នាំ ។

ដោយសារ "ការប៉ះពាល់ដល់វិស័យយុត្តិធម៌" ដែលជាបទល្មើសប្រឆាំងនឹងមនុស្សជាតិ ឬទ្រព្យសម្បត្តិ គ្រប់សមាជិកសង្គម ជាពិសេសសមាជិកក្នុងសហគមន៍ច្បាប់ គឺជាជនរងគ្រោះដោយបទល្មើសទាំងនេះ[16]។

៤ អនុលោមតាមក្រមព្រហ្មទណ្ឌ "បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ"[17]។ ការទទួលខុសត្រូវចំពោះទង្វើបែបនេះអាចកើតឡើងតាមវិធីផ្សេងៗ រួមទាំង៖ (១) ចារី[18] (២) សហចារី[19] (៣) ការប៉ុនប៉ង[20] (៤) អ្នកផ្តើមគំនិត[21] និង/ឬ (៥) អ្នកសមគំនិត[22]។

៥ អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ហៅថា "រដ្ឋធម្មនុញ្ញ") មន្ត្រីរដ្ឋាភិបាលជាក់លាក់ដែលទទួលផលប្រយោជន៍មានដែនកំណត់ ពីអភ័យឯកសិទ្ធិ។ ជាពិសេស៖

> មាត្រា ៨០៖
> អនុប្រធានរដ្ឋសភាមានអភ័យឯកសិទ្ធិ។
>
> តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួនឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។
>
> ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង [...]។
>
> មាត្រា ១០៤៖
> សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា។

---

[16] សូមមើលមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ("ជនរងគ្រោះនៃបទឧក្រិដ្ឋដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើសអាចដាក់ពាក្យប្តឹង) ។

[17] ក្រមព្រហ្មទណ្ឌ មាត្រា ២៤។

[18] ក្រមព្រហ្មទណ្ឌ មាត្រា ២៥។

[19] ក្រមព្រហ្មទណ្ឌ មាត្រា ២៦។

[20] ក្រមព្រហ្មទណ្ឌ មាត្រា ២៧។

[21] ក្រមព្រហ្មទណ្ឌ មាត្រា ២៨។

[22] ក្រមព្រហ្មទណ្ឌ មាត្រា ២៩។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃព្រឹទ្ធសភា នឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង [...]។

**មាត្រា ១២៦៖**
សមាជិកមួយរូបៗ នៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន។

ក្នុងករណីនេះ និង ក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសំរេចប្តឹងទៅតុលាការមានសមត្ថកិច្ច។

រដ្ឋសភាសំរេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។

អាស្រ័យហេតុនេះហើយ គ្រប់សមាជិករដ្ឋសភា និងព្រឹទ្ធសភា បើទោះបីជាមានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ *ទាក់ទិន នឹងការងារច្បាប់របស់ខ្លួន* ក៏ប៉ុន្តែគាត់មិនមានអភ័យឯកសិទ្ធិណាមួយក្រៅអំពីការងារសភា ដូចជាការងារធ្វើឲ្យប៉ះពាល់ដល់តុលាការ ដែលជាផ្នែកឯករាជ្យពីរាជរដ្ឋាភិបាល[23]។ គ្រប់សមាជិករាជរដ្ឋាភិបាលទាំងអស់ ក៏ដូចជាប្រជាជនកម្ពុជាធម្មតាដែរ ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្ត *នៅក្រៅវង្វង់ការងារផ្លូវការរបស់ខ្លួន*។

## IV **អំណះអំណាង**

៦ ដោយពិចារណាលើអង្គហេតុដែលបានរៀបរាប់ខាងលើ សមាជិករាជរដ្ឋាភិបាលមួយចំនួនបានប្រព្រឹត្ត "ការប៉ះពាល់ដល់វិស័យយុត្តិធម៌"៖

ក. ដោយការបំពាន ដីកាកោះរបស់ សហចៅក្រមស៊ើបអង្កេត និងការបដិសេធមិនព្រមចូលផ្តល់សក្ខីកម្មដោយមិនមានហេតុផលត្រឹមត្រូវ[24] **ជា ស៊ីម, ហេង សំរិន, ហោ ណាំហុង,**

[23] សូមមើលមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញ ("អំណាចបែងចែកដាច់ពីគ្នា "រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

[24] សូមមើលកថាខណ្ឌទី២(គ) ខាងលើ ។

**គាត ឈន់, អ៊ុក ប៊ុនឈឿន និង ស៊ុម កា** បានប្រព្រឹត្តបទល្មើសនៃ "បទបដិសេធក្នុងការចូលខ្លួន" ដែលអាចដាក់ទណ្ឌកម្មបានតាមមាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌ ដោយការដាក់ពន្ធនាគារ និងពិន័យជាប្រាក់។

ខ. ដោយការបញ្ចេញជាសាធារណៈ និងជាក់ស្តែងនូវទស្សនៈផ្ទាល់ខ្លួន និង/ឬដោយនៅក្រៅរង្វង់ការងារផ្លូវការរបស់ខ្លួន អំពីថាតើករណី ០០៣ និង ០០៤ នៅអវតក គួរតែដំណើរការឬក៏អត់[25] លោក **ខៀវ សុភ័គ, ហ៊ុន សែន, ខៀវ កាញារិទ្ធ, ហោ ណាំហុង និង ផៃ ស៊ីផាន** បានប្រព្រឹត្តបទល្មើស "បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដើម្បីធ្វើសម្ពាធលើយុត្តាធិការ" ដែលអាចដាក់ទណ្ឌកម្មបានតាមមាត្រា ៥២២ ក្រមព្រហ្មទណ្ឌដោយការដាក់ពន្ធនាគារ និងពិន័យជាប្រាក់។ ការបញ្ចេញទស្សនៈបែបនេះ គឺមានបំណងច្បាស់លាស់ក្នុងការដាក់សម្ពាធលើ អវតក ដើម្បីបញ្ចប់ករណី ០០៣ និង ០០៤ នៅមុនពេលសេចក្តីសម្រេចចុងក្រោយរបស់តុលាការ។

គ. ដោយសារបដិសេធមិនព្រមបញ្ជូនលិខិតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត យាងព្រះករុណាដើម្បីផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ឲ្យទៅដល់ព្រះរាជបីតា[26] **គង់ សំអុល** បានប្រព្រឹត្តបទល្មើស "បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ" អាចដាក់ទណ្ឌកម្មបានតាមមាត្រា ៥២០ ឬ ៥២៥ នៃក្រមព្រហ្មទណ្ឌ ដោយការដាក់ពន្ធនាគារ និងពិន័យជាប្រាក់។ លើសពីនេះ ឬអាចនិយាយម្យ៉ាងទៀតថា **គង់ សំអុល** បានប្រព្រឹត្តដូចគ្នាដោយបំពាននឹងមាត្រា ៥៤៦ និង/ឬ ៥៨៦ នៃក្រមព្រហ្មទណ្ឌ។ តាមបញ្ញត្តិពីរចុងក្រោយនេះ ដោយសារតែបទល្មើសនេះសម្តែងចេញជាលទ្ធផល ដោយធ្វើឲ្យមិនអាចទទួលបានសក្ខីកម្ម។ ទង្វើនេះអាចដាក់ពន្ធនាគារបន្ថែមទៀត។

ឃ. ដោយការបញ្ចេញជាសាធារណៈ និងជាក់ស្តែងនូវទស្សនៈផ្ទាល់ខ្លួន និង/ឬដោយនៅក្រៅរង្វង់ការងារផ្លូវការរបស់ខ្លួន ថាតើសាក្សីខាងក្នុងទាំងប្រាំមួយរូបគួរផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ នៅអវតក[27] **ខៀវ កាញារិទ្ធ** បានប្រព្រឹត្តបទល្មើស "បទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់លើសាក្សី" អាចដាក់ទណ្ឌកម្មបានតាមមាត្រា ៥៤៩ នៃក្រមព្រហ្មទណ្ឌ ដោយដាក់ពន្ធនាគារ និងពិន័យជាប្រាក់។ ការបញ្ចេញទស្សនៈបែបនេះ មានគោល

---

[25] សូមមើលកថាខណ្ឌទី ២(ង)-(ញ) ខាងលើ ។

[26] សូមមើលកថាខណ្ឌទី ២(ឃ) ។

[27] សូមមើលកថាខណ្ឌទី ២(ឃ) ។

បំណងយ៉ាងច្បាស់ក្នុងការដាក់សម្ពាធលើសាក្សីខាងក្នុងទាំងប្រាំមួយរូប។ បន្ថែមពីនេះ **ខៀវ កាញារិទ្ធ** បានប្រព្រឹត្តបទល្មើសដូចគ្នា ដោយបំពានលើមាត្រា ៥៤៦ នៃក្រមព្រហ្មទណ្ឌ។

ង. ជាចុងក្រោយ ដោយការបញ្ចេញជាសាធារណៈ និងដាក់ស្តែងនូវទស្សនៈផ្ទាល់ខ្លួន និង/ឬ ដោយនៅក្រៅរង្វង់ការងារផ្លូវការរបស់ខ្លួន ថាតើសាក្សីគួរផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ នៅ អវតក[28] **ហ៊ុន សែន** បានប្រព្រឹត្តបទល្មើស "បទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់លើសាក្សី" អាចដាក់ទណ្ឌកម្មបានតាមមាត្រា ៥៤៩ នៃក្រមព្រហ្មទណ្ឌ ដោយដាក់ពន្ធនាគារ និងពិន័យជាប្រាក់។ ការបញ្ចេញទស្សនៈបែបនេះ មានគោលបំណងយ៉ាងច្បាស់ក្នុងដាក់សម្ពាធលើសាក្សីមិនឱ្យផ្តល់សក្ខីកម្មនៅ អវតក។ បន្ថែមពីនេះ **ហ៊ុន សែន** បានប្រព្រឹត្តបទល្មើសដូចគ្នា ដោយបំពានមាត្រា ៥៤៦ នៃក្រមព្រហ្មទណ្ឌ។

ការរារាំងពីអំណាចនីតិប្រតិបត្តិ នៅក្នុងការងារមួយ ដែលត្រូវតែជាផ្នែកតុលាការឯករាជ្យ គឺវាផ្ទុយនឹងគោលការណ៍បែងចែកអំណាច ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ, និង គម្រាបកំហែងដើម្បីបន្ទាបបន្ថោកយ៉ាងជ្រុលហួសហេតុលើអធិបតេយ្យភាពនៃដំណើរការក្នុងសំណុំរឿង ០០២ នៅ អវតក និង យ៉ាងសាមញ្ញបំផុត ចាត់ទុកថា ជាបទល្មើសព្រហ្មទណ្ឌ តាមក្រមព្រហ្មទណ្ឌ។

៧ មន្ត្រីរដ្ឋាភិបាលដែលមានឈ្មោះខាងលើ គឺទទួលខុសត្រូវព្រហ្មទណ្ឌ ជាចារី[29] នូវបទល្មើសដែលមានក្នុងកថាខណ្ឌខាងលើ។ ជាងនេះទៅទៀត វាហាក់ដូចជាឃើញថា "ដោយមានការព្រមព្រៀងគ្នា" មន្ត្រីទាំងអស់នេះប្រព្រឹត្តឡើងនូវផែនការព្រហ្មទណ្ឌមួយគឺ "ការប៉ះពាល់ដល់វិស័យយុត្តិធម៌" នៅ អវតក។ ដូចនេះគាត់ទទួលខុសត្រូវដូចគ្នាក្នុងនាមជា សហចារី[30]។ បន្ថែមពីលើនេះ **ហ៊ុន សែន, ខៀវ សុផ័គ, ខៀវ កាញារិទ្ធ, ហោ ណាំហុង, និង ផៃ ស៊ីផាន** ក៏គឺជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងនាមជាអ្នកផ្តើមគំនិត[31]។ និងនិយាយម្យ៉ាងទៀត អ្នកទាំងបួនខាងក្រោយគឺទទួលខុសត្រូវក្នុងនាមជាអ្នកសមគំនិត[32] ជាមួយចារី និងជាអ្នកធ្វើឱ្យមានការខំប្រឹងប្រែងរារាំងរបស់រដ្ឋាភិបាល គឺលោក **ហ៊ុន សែន**។

---

[28] សូមមើលកថាខណ្ឌទី២(ខ) ខាងលើ ។

[29] សូមមើល ក្រមព្រហ្មទណ្ឌ មាត្រា ២៥។

[30] សូមមើល ក្រមព្រហ្មទណ្ឌ មាត្រា ២៦។

[31] សូមមើល ក្រមព្រហ្មទណ្ឌ មាត្រា ២៨។

[32] សូមមើល ក្រមព្រហ្មទណ្ឌ មាត្រា ២៩។

៨ ចំពោះអ្វីដែលបានរៀបរាប់ក្នុងកថាខណ្ឌ ៥ (ក) **ជា ស៊ីម, ហេង សំរិន, អ៊ុក ប៊ុនឈឿន** និង **ស៊ីម កា** មិនអាចជួយខ្លួន ដោយប្រើអភ័យឯកសិទ្ធិ ដែលមានក្នុងមាត្រា ៨០ ឬ ១០៤ នៃរដ្ឋធម្មនុញ្ញ[33] ឡើយ។ ការបដិសេធមិនចូលខ្លួនតាមដីកា ទោះជាតាមវិធីណាក៏ដោយ ក៏មិនអាចចាត់ទុកថា ជាការបញ្ចេញ មតិយោបល់របស់ខ្លួនក្នុងពេលបំពេញមុខងារឡើយ។

៩ ការលើកឡើងប្រឆាំងនឹងបុគ្គលទាំងអស់ខាងលើនេះ គ្មានសកម្មភាពព្រហ្មទណ្ឌណាមួយ ដែលត្រូវបានចោទប្រកាន់ក្នុងបណ្តឹងនេះ ត្រូវបានចាត់ទុកថា "ប្រព្រឹត្តឡើងក្នុងពេលបំពេញ [...] កាតព្វកិច្ច"[34] នោះទេ។ អាស្រ័យហេតុនេះហើយ ការិយាល័យព្រះរាជអាជ្ញា នៃតុលាការក្រុងភ្នំពេញ មិនត្រូវសុំការអនុញ្ញាត ឬពិភាក្សា ជាមួយរដ្ឋសភា ដើម្បីបន្តការស៊ើបអង្កេត និងការចោទប្រកាន់ចំពោះអ្នកប្រព្រឹត្តិបទល្មើសខាងលើនេះឡើយ។

## V. សំណើសុំដំណោះស្រាយ

១០ អាស្រ័យហេតុនេះ ដើមបណ្តឹង សូមស្នើ ការិយាល័យព្រះរាជអាជ្ញា នៃតុលាការក្រុងភ្នំពេញ ចាប់ផ្តើមសំណុំរឿងព្រហ្មទណ្ឌ (តាមរយៈការស៊ើបអង្កេត) ដោយអនុលោមតាមមាត្រា ៤៣ និង ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹង **ជា ស៊ីម, ហេង សំរិន, ហោ ណាំហុង, គាត ឈន់, អ៊ុក ប៊ុនឈឿន, ស៊ីម កា, ខៀវ សុភ័គ, ហ៊ុន សែន, ខៀវ កាញារិទ្ធ, ផៃ ស៊ីផាន និង គង់ សំអុល**[35]។

ធ្វើនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

Michiel PESTMAN Andrew IANUZZI

[33] សូមមើលកថាខណ្ឌទី៤ ខាងលើ ។

[34] សូមមើលរដ្ឋធម្មនុញ្ញ នៅមាត្រា ១២៦ ។

[35] កំណត់សំគាល់៖ ដោយមិនគិតថាតើចារីដែលត្រូវបានគេបង្ហាញឈ្មោះ គឺជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែរ ឬយ៉ាងទេ, ម្ចាស់ពាក្យបណ្តឹងមិនបានជូនដំណឹងដល់ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ នៅមុខពេលដាក់ពាក្យបណ្តឹងនេះ ។ សូមមើលក្រមសីលធម៌មេធាវីដែលត្រូវបានអនុញ្ញាតិឲ្យប្រកបវិជ្ជាជីវៈដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៦ ចែងថា: ការប្តឹងទៅតុលាការ ("ប្រធានគណៈមេធាវី ត្រូវតែបានជូនដំណឹងជាមុន មុននឹងមេធាវីណាចាប់ផ្តើមប្តឹងតាមផ្លូវតុលាការពីមេធាវីណាមួយទៀត ឬ ពីចៅក្រម ឬ សមាជិកណាមួយទៀតនៃវាល់វិជ្ជាជីវៈគតិយុត្តិ ឬ តុលាការណាដែលមានច្បាប់គ្រប់ ។